# វិញ្ញាសារប្រលងសាកល្បង

# សំណួរ

## សម័យប្រលងខែមិថុនា ឆ្នាំ2018

**រយៈពេលអនុញ្ញាត**

អំនាន និងគ្រោងគំនិតលើចម្លើយ : 15នាទី
សំណេរ : 3ម៉ោង

តម្រូវឲ្យឆ្លើយគ្រប់សំណួរទាំងប្រាំ។
អត្រាពន្ធ និងប្រាក់បន្ថយមូលដ្ឋានកំណត់ពន្ធមានបង្ហាញនៅទំព័រទី1 និងទី2។

**ហាមបើកវិញ្ញាសារប្រឡងរហូតទាល់តែមានការអនុញ្ញាតពីមេប្រយោគ។**

ក្នុងអំឡុងពេលធ្វើអំនាន និងគ្រោងគំនិត បេក្ខជនប្រលងអាចកត់ត្រាបានតែលើវិញ្ញាសារប្រលងតែប៉ុណ្ណោះ។ បេក្ខជនប្រលង**មិន**ត្រូវសរសេរលើក្រដាសចម្លើយ រហូតទាល់តែមានការអនុញ្ញាតពីមេប្រយោគ។

វិញ្ញាសារប្រលងមិនត្រូវយកចេញពីបន្ទប់ប្រលងឡើយ។

សារពើពន្ធកម្ពុជា

## ការណែនាំបន្ថែម

1. រាល់ការគណនា និងចម្លើយ តម្រូវអោយគណនាត្រឹមលេខគត់ជាប្រាក់ដុល្លារ ឬប្រាក់រៀល។ ចំនួនលេខស្មើនឹង 0.5 ឡើងទៅត្រូវបង្គ្រប់អោយស្មើ 1។
2. រាល់ការបែងចែកទាំងអស់ តម្រូវអោយគិតត្រឹមតែខែដែលកៀកបំផុត។
3. រាល់ការងារគណនាទាំងអស់ តម្រូវអោយបង្ហាញ លើកលែងតែសំណួរជ្រើសរើស។
4. ដើម្បីទទួលបានពិន្ទុ រាល់ការគណនាគួរត្រូវបញ្ជាក់ដោយប្រើសញ្ញាលេខសូន្យ "0" អោយបានសមស្របចំពោះចំណូល ឬ ចំណាយលើកលែងពន្ធ មិនជាប់ពន្ធ ឬក៏មិនតម្រូវអោយធ្វើនិយ័តកម្ម។

## អត្រាពន្ធ និង ប្រាក់បន្ថយមូលដ្ឋានកំណត់ពន្ធផ្សេងៗ

ខាងក្រោមនេះគឺជាអត្រាពន្ធ និងប្រាក់បន្ថយមូលដ្ឋានកំណត់ពន្ធផ្សេងៗសម្រាប់ប្រើក្នុងការឆ្លើយសំនួរ។

## អាករលើតម្លៃបន្ថែម (អតប)

អត្រាស្តង់ដា: 10%
ការនាំចេញ: 0%
ការផ្គត់ផ្គង់មិនជាប់អាករ: មិនគិត អតប (ការទិញមិនអាចស្នើសុំឥណទានលើធាតុចូល)

## ពន្ធលើប្រាក់ចំណេញ (ពបច)

អត្រាស្តង់ដា: 20%
រយៈពេលលើកលែងពន្ធ: 0%

## ពន្ធកាត់ទុក

ពន្ធកាត់ទុកលើចំណូលការប្រាក់ពីគណនីសន្សំមានកាលកំណត់ជាមួយធនាគារក្នុងស្រុក: 6%
ពន្ធកាត់ទុកលើចំណូលការប្រាក់ពីគណនីសន្សំគ្មានកាលកំណត់ជាមួយធនាគារក្នុងស្រុក: 4%

## ពន្ធលើប្រាក់បៀវត្ស (ពបវ)

ប្រាក់បន្ថយមូលដ្ឋានកំណត់ពន្ធចំពោះកូនក្នុងបន្ទុក និងសហព័ទ្ធដែលមិនមានការងារធ្វើខាងក្រៅគឺ 150,000 រៀល សម្រាប់ម្នាក់ក្នុងមួយខែ។

### <u>អត្រា ពបវ សម្រាប់និវាសនជន</u>

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ (រៀល) | ប្រាក់ពន្ធបូកបន្តនៃកំរិតប្រាក់បៀវត្ស ខ្ពស់បំផុតក្នុងចន្លោះនីមួយៗ | អត្រាពន្ធ |
|---|---|---|
| 0 – 1,200,000 | 0 | 0% |
| 1,200,001 – 2,000,000 | 40,000 | 5% |
| 2,000,001 – 8,500,000 | 690,000 | 10% |
| 8,500,001 – 12,500,000 | 1,290,000 | 15% |
| 12,500,001 ឡើងទៅ | | 20% |

**<u>អត្រា ពបវ សម្រាប់អនិវាសនជន</u>**
**អត្រាថេរ**: 20%

**ពន្ធលើអត្ថប្រយោជន៍បន្ថែម**
**អត្រាថេរ**: 20%

**អាករបំភ្លឺសាធារណៈ**
អត្រា 3%

**អាករលើការស្នាក់នៅ**
អត្រា 2%

**អាករពិសេសលើទំនិញ និងសេវាមួយចំនួន**
អត្រា 3%, 10%, 30% ឬ 35% .. យោងតាមប្រភេទទំនិញ និងសេវា

**តម្រូវឱ្យឆ្លើយគ្រប់សំណួរទាំងប្រាំ។**

សំណួរទី1- សំណួរជ្រើសរើស (សំណួរនីមួយៗទទួលបាន 2ពិន្ទុ)

i. ABC Co., Ltd បានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។ សម្រាប់ការិយបរិច្ឆេទថ្ងៃទី 31 ខែធ្នូ ឆ្នាំ2016 ក្រុមហ៊ុនបានកត់ត្រានូវប្រតិបត្តិការក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដូចខាងក្រោម៖

1. ការខាតបង់ពីការលក់ទ្រព្យសកម្មដូចបានកត់ត្រាក្នុងបញ្ជីគណនេយ្យ
2. ចំណាយលើការកំសាន្តរបស់បុគ្គលិក ដែលក្នុងនោះពន្ធលើអត្ថប្រយោជន៍បន្ថែម ចំនួន 20% បានបង់។
3. ចំណាយលើការកំសាន្តរបស់អតិថិជន
4. ការខាតបង់លើការលក់ដីមួយកន្លែងទៅបុគ្គលទាក់ទិន។

តើចំណាយខាងលើណាខ្លះជាចំណាយដែលមិនអាចកាត់កងបាន?

A. 1 និង 2
B. 1, 2 និង 3
C. 1, 3 និង 4
**D.** 1 និង 4

ii. ក្រុមហ៊ុន ABC ស្ថិតក្នុងចំណាច់ថ្នាក់ជាអ្នកជាប់ពន្ធធំ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអ្នកជាប់ពន្ធធំ។ ក្នុងឆ្នាំ2016 ក្រុមហ៊ុន ABC បានបង់ពន្ធប៉ាតង់ឆ្នាំ2016 ចំនួន 3,000,000 រៀល មុនថ្ងៃទី31 ខែមីនា ឆ្នាំ2016។ ក្នុងឆ្នាំ2016 ក្រុមហ៊ុន ABC មានផលរបរប្រចាំឆ្នាំចំនួន 9,000 លានរៀល។ តើក្រុមហ៊ុន ABC ត្រូវបង់ពន្ធប៉ាតង់ឆ្នាំ2017 ចំនួនប៉ុន្មាន?

A. 1,140,000 រៀល
B. 1,200,000 រៀល
C. 3,000,000 រៀល
D. 5,000,000 រៀល

iii. យោងតាមមាត្រា 32 នៃប្រកាសស្តីពីអតប ក្នុងករណីទំនិញ ឬសេវាទិញចូល ត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អតប និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អតប ឥណទានអតបត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អតប ប៉ុណ្ណោះ។ ក្នុងចំណោមវិធីផ្សេងៗ អតបលើធាតុចូល ដែលអាចផ្តល់ឱ្យត្រូវបានគណនាតាមរូបមន្ត : **ក x ខ/គ**

1. ក្នុងករណីដែលប្រភាគ ខ/គ តិចជាង 0.05 ឥណទានអតបលើធាតុចូលទាំងអស់ដែលគិតដោយអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱ្យជា អតបលើធាតុចូលក្នុងរយៈពេលជាប់អតប។
2. ក្នុងករណីដែលប្រភាគ ខ/គ តិចជាង 0.05 ចំនួន 5% នៃអតបសរុប ដែលគិតដោយអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱ្យជាអតបលើធាតុចូលក្នុងរយៈពេលជាប់អតប។
3. ក្នុងករណីដែលប្រភាគ ខ/គ ច្រើនជាង 0.95 ចំនួនអតប ទាំងអស់ ដែលគិតដោយអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱ្យជាអតបលើធាតុចូលក្នុងរយៈពេលជាប់អតប។
4. ក្នុងករណីដែលប្រភាគ ខ/គ ច្រើនជាង 0.95 ចំនួន 95% នៃអតបសរុប ដែលគិតដោយអ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱ្យជាអតបលើធាតុចូលក្នុងរយៈពេលជាប់អតប។

តើចំណុចណាមួយ /ខ្លះខាងលើដែលត្រឹមត្រូវ?

A. 1, និង 2
B. 2, និង 3
C. 3 តែប៉ុណ្ណោះ
D. 4តែប៉ុណ្ណោះ

iv. I-food Import and Export Co., Ltd, បាននាំចូលទំនិញមួយចំនួនពីបរទេស។ ថ្លៃដើមដែលពាក់ព័ន្ធនៃទំនិញនាំចូលមានដូចខាងក្រោម៖

1. ថ្លៃទំនិញគិតដោយអ្នកផ្គត់ផ្គង់
2. ថ្លៃដឹកជញ្ជូន (Freight charge) លើទំនិញនាំចូល
3. ថ្លៃធានារ៉ាប់រងបង់លើទំនិញ ក្នុងកំឡុងពេលដឹកជញ្ជូន
4. ពន្ធគយលើការនាំចូល(Customs duty on import)
5. អាករពិសេសលើការនាំចូល

តើមូលដ្ឋានសម្រាប់គណនា អតប លើការនាំចូលទំនិញខាងលើជាអ្វី?

A. 1+2+3+4
B. 1+2+4+5
C. 1+3+4+5
D. 1+2+3+4+5

v. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(សហវ) បានចេញសារាចរណែនាំលេខ 002 ចុះថ្ងៃទី20 ខែមករា ឆ្នាំ2015 ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម។ យោងតាមសារាចរនេះ សហវ បានផ្តល់ការ

លើកលែងពីពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម ចំពោះការឧបត្ថម្ភ និងផលប្រយោជន៍មួយចំនួនដែលផ្តល់ទៅឱ្យនិយោជិត កម្មករ កម្មការិនី នៃរោងចក្រនានា។

ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ទាំងនេះមានជាអាទិ៍៖

1. សោហ៊ុយធ្វើដំណើរពីទីកន្លែងស្នាក់នៅ ទៅទីកន្លែងធ្វើការ ឬរោងចក្រ និងពីទីកន្លែងធ្វើការ ឬរោងចក្រទៅកន្លែងស្នាក់នៅ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។
2. ប្រាក់ថ្លៃបាយដែលផ្តល់ឱ្យនិយោជិត កម្មករ កម្មការិនីទាំងអស់ដោយគ្មានបែងចែកតាមតួនាទី ឬមុខងារ រួមទាំងប្រាក់ថ្លៃបាយបន្ថែមម៉ោង។
3. ការឧបត្ថម្ភថ្លៃស្នាក់នៅ ឬការផ្តល់បរិក្ខារ(facilities) ស្នាក់នៅទាំងនៅក្នុងបរិវេណរោងចក្រ និងក្រៅបរិវេណរោងចក្រស្របតាមបទប្បញ្ញត្តិនៃច្បាប់ការងារ។
4. ប្រាក់ធានារ៉ាប់រងសុខភាព និងធានារ៉ាប់រងរថយន្ត ដែលផ្តល់ឱ្យនិយោជិត កម្មករ កម្មការិនីទាំងអស់ដោយគ្មានបែងចែកតាម តួនាទី ឬមុខងារ

តើចំណុចណាមួយខាងលើដែលត្រឹមត្រូវ?

A. 1 និង 2
B. 1, 2, និង 3
C. 1, 2, 3 និង 4
D. 2, 3 និង 4

vi. តើចំណុចខាងក្រោមណាខ្លះដែលត្រឹមត្រូវ ដែលទាក់ទិនទៅនឹងរំលស់ពិសេស៖

1. រំលស់ពិសេសត្រូវបានអនុញ្ញាត សំរាប់ គ.ល.គដែលមិនជ្រើសរើសប្រើប្រាស់សិទ្ធិនៃរយៈពេលលើកលែងពន្ធប៉ុណ្ណោះ។
2. រំលស់ពិសេសត្រូវបានគណនាស្មើនឹង 50% នៃថ្លៃដើមនៃទ្រព្យរូបីថ្មី និង/ឬ ទ្រព្យរូបីដែលធ្លាប់ប្រើប្រាស់រួច ដែលបានប្រើប្រាស់ក្នុងការផលិត និងកែច្នៃ នៃ គ.ល.គ ។
3. ទ្រព្យរូបីទាំងឡាយណាដែលបានប្រកាសថាប្រើប្រាស់រំលស់ពិសេសត្រូវ ប្រើប្រាស់ដោយ គ.ល.គ សម្រាប់រយៈពេលយ៉ាងតិចបំផុតបី (3)ឆ្នាំ។

A. 1 តែប៉ុណ្ណោះ
B. 1 និង 2
C. 2 និង 3
D. 3 តែប៉ុណ្ណោះ

vii. លោកតារា មានផ្ទះល្វែងមួយខ្នង ដែលស្ថិតនៅមហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ7មករា រាជធានីភ្នំពេញ។ ផ្ទះល្វែងរបស់គាត់មានផ្ទៃដី 80 ម៉ែត្រការ៉េ ដែលជាន់ផ្ទាល់ដីមានទំហំ 64ម៉ែត្រការ៉េ និងជាន់ទី1 មានទំហំ 72 ម៉ែត្រការ៉េ។ យោងតាមឧបសម្ព័ន្ធទី1(ថ្មី)ស្តីពីតម្លៃអចលនទ្រព្យ 1(ថ្មី) ចុះថ្ងៃទី1 ខែកញ្ញា ឆ្នាំ2014 នៃប្រកាសលេខ 371 សហវ.ប្រក ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្ទះល្វែងរបស់លោកតារាត្រូវកំណត់តម្លៃដូចខាងក្រោម៖

- ដី – កំណត់តម្លៃស្មើនឹង 1,500 ដុល្លា ក្នុង 1 ម៉ែត្រការ៉េ។
- ជាន់ផ្ទាល់ដី– កំណត់តម្លៃស្មើនឹង 250ដុល្លា ក្នុង 1 ម៉ែត្រការ៉េ។
- ជាន់ទី1 – កំណត់តម្លៃស្មើនឹង 200ដុល្លា ក្នុង 1 ម៉ែត្រការ៉េ។

(អត្រាប្តូរប្រាក់ 1ដុល្លា = 4,000 រៀល)

សម្រាប់ឆ្នាំ 2017 លោកតារាត្រូវបង់ពន្ធលើអចលនទ្រព្យលើផ្ទះល្វែងរបស់គាត់ក្នុងចំនួន៖

A. 381,280 រៀល
B. 501,600 រៀល
C. 481,280 រៀល
D. 3,812,800 រៀល

viii. ឧត្តម លីបានបំរើការងារជាអ្នកគ្រប់គ្រងទូទៅ នៅក្រុមហ៊ុន ABE Co., Ltd. (ABE) ដែលជាក្រុមហ៊ុនកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ។ សំរាប់ខែកុម្ភៈ ឆ្នាំ2017 ក្រុមហ៊ុន ABE បានទូទាត់ប្រាក់ជូនឧត្តម ដូចខាងក្រោម:

- ប្រាក់បៀវត្សមូលដ្ឋានចំនួន 2,500ដុល្លារ បានបញ្ចូលទៅក្នុងគណនីធនាគាររបស់គាត់នៅចុងខែកុម្ភៈ ឆ្នាំ2017។
- ប្រាក់បុរេប្រទាននៃប្រាក់បៀវត្សសម្រាប់ខែមីនា ឆ្នាំ2017 ចំនួន500ដុល្លារ។ ប្រាក់បុរេប្រទាននេះ ត្រូវបានបញ្ចូលទៅក្នុងគណនីធនាគាររបស់គាត់នៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2017។
- បុព្វលាភធានារ៉ាប់រងសុខភាពចំនួន 450 ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់និយោជិតម្នាក់ៗ។ បុព្វលាភធានារ៉ាប់រងនេះ ផ្តល់អោយនិយោជិតគ្រប់គ្នា និងបានទូទាត់ទៅអោយក្រុមហ៊ុនធានារ៉ាប់រងរៀងរាល់ខែកុម្ភៈ។
- ឈ្នួលផ្ទះចំនួន 300ដុល្លារ ក្នុងមួយខែ ដែលនិយោជកទូទាត់ទៅអោយម្ចាស់ផ្ទះដោយផ្ទាល់នៅរៀងរាល់ដើមខែ។ ក្រុមហ៊ុនបង់ឈ្នួលផ្ទះសម្រាប់តែគាត់ម្នាក់គត់។
- ប្រាក់សំណងលើវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង៖ 350ដុល្លារ
- ប្រាក់បង្វិលសងវិញលើថ្លៃសាលារៀនសម្រាប់កូនស្រីទាំង2របស់គាត់៖ 700ដុល្លារ។
- ប្រាក់បង្វិលសងវិញលើថ្លៃចំណាយពិតលើការធ្វើដំណើរទៅទីក្រុងហុងកុង(រួមមានថ្លៃសំបុត្រយន្តហោះ ការស្នាក់នៅ និងអាហារ) សំរាប់ការចូលរួមប្រជុំជាមួយនឹងអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុន។ គាត់បានប្រើប្រាស់ប័ណ្ណឥណទានរបស់គាត់ដើម្បីទូទាត់ចំណាយទាំងអស់នេះ ដែលមានទឹកប្រាក់សរុបចំនួន 1,500ដុល្លារ។

- ឧត្តម មានកូនស្រី 2នាក់ ម្នាក់អាយុ 7ឆ្នាំ និងម្នាក់ទៀតអាយុ 11 ឆ្នាំ។ ភរិយារបស់គាត់ក៏កំពុង បំរើការងារក្នុងប្រទេសកម្ពុជាដែរ ហើយនាងបានប្រកាសប្រាក់កាត់កងសំរាប់កូននៅក្នុងបន្ទុកទាំងពីរនាក់រួចហើយ។
- ឧត្តម ត្រូវមើលថែម្តាយចាស់ជរារបស់គាត់ម្នាក់នៅប្រទេសកម្ពុជា។ ម្តាយរបស់គាត់រស់នៅពឹងផ្អែកទាំងស្រុងលើគាត់។

**សន្មតថា អត្រាប្តូរប្រាក់ក្នុងមួយដុល្លារស្មើនឹង 4,000រៀល ចូរគណនាជាប្រាក់រៀលនូវបំណុលពន្ធលើប្រាក់បៀវត្សរបស់ឧត្តម សំរាប់ខែកុម្ភៈ ឆ្នាំ2017។**

A. 950,000 Riel
B. 1,250,000 Riel
C. 1,205,000 Riel
D. 2,365,000 Riel

ix. **ផ្អែកលើព័ត៌មានក្នុងសំណួរទី (viii) ចូរគណនាជាប្រាក់រៀលនូវបំណុលពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់ឧត្តម សំរាប់ខែកុម្ភៈ ឆ្នាំ2017 (សន្មតថា អត្រាប្តូរប្រាក់ក្នុងមួយដុល្លារស្មើនឹង 4,000រៀល)។**

A. 1,200,000 Riel
B. 640,000 Riel
C. 1,440,000 Riel
D. 800,000 Riel

x. **តើប្រភេទនៃការផ្គត់ផ្គង់ណាខ្លះដែលបុគ្គលជាប់អាករមិនអាចស្នើសុំឥណទានអតបលើធាតុចូលចំពោះប្រាក់អាករដែលបានបង់លើការទិញ ឬការនាំចូល?សន្មតថារាល់អ្នកផ្គត់ផ្គង់ជាក្រុមហ៊ុនចុះបញ្ជីអតប។**

1- ចំណាយទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ លើកលែងតែបុគ្គលជាប់អាករលើតម្លៃបន្ថែម មានអាជីវកម្មជាអ្នកផ្គត់ផ្គង់ការទទួលភ្ញៀវ ការកំសាន្ត ឬការសម្រាកលំហែ។
2- ការទិញ ឬការនាំចូលរថយន្ត លើកលែងតែបុគ្គលជាប់អាករលើតម្លៃបន្ថែមប្រកបអាជីវកម្មជាអ្នកលក់ ឬជួលរថយន្ត។
3- ការទិញ ឬការនាំចូលផលិតផលតេលសិលាមួយចំនួន លើកលែងតែបុគ្គលជាប់អាករលើតម្លៃបន្ថែមប្រកបអាជីវកម្មជាអ្នកផ្គត់ផ្គង់ផលិតផលតេលសិលាទាំងនោះ។
4- ចំណាយលើសេវាអ៊ីធើណែត។

A. 1 និង 2
B. 3 និង 4
C. 1, 2 និង 3
D. ចំណុចទាំងអស់ខាងលើ

**xi.** EFG Co., Ltd ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIP)ផ្តោតលើនាំចេញ បានចុះបញ្ជីដោយត្រឹមត្រូវជាមួយអាជ្ញាធរមូលដ្ឋានកម្ពុជា ជារោងចក្រផលិតស្បែកជើងតាំងពីឆ្នាំ2011។ រយៈពេលលើកលែងពន្ធរបស់ EFG បញ្ចប់ក្នុងឆ្នាំ2015 ដូចនេះរោងចក្រនេះនឹងត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រា 20% ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2016 តទៅ។

ខាងក្រោមនេះជាប្រតិបត្តិការទិញ និងលក់លម្អិតរបស់EFG ក្នុងខែឧសភា ឆ្នាំ2016៖

1. លក់ស្បែកជើង(នាំចេញ)៖ 250,000 ដុល្លារ
2. ចំណាយជួលរោងចក្រ៖ 2,530 ដុល្លារ រួមបញ្ចូល អតប
3. ថ្លៃបច្ចេកទេសបង់ទៅជនបរទេស (expatriate) អនិវាសជន៖ 1,000ដុល្លារ
4. ចំណាយការប្រាក់បង់ទៅធនាគារក្នុងស្រុកដែលជាបុគ្គលទាក់ទិន ៖ 2,400 ដុល្លារ

ចូរគណនាបំណុលពន្ធប្រចាំខែរបស់ EFG សម្រាប់ខែឧសភា ឆ្នាំ2016 (ដោយប្រើប្រាស់អត្រាប្តូរប្រាក់ក្នុង 1ដុល្លារ ៖ 4,063 រៀល)

A. 1,503,310 រៀល
B. 11,660,810 រៀល
C. 13,123,490 រៀល
D. 2,965,990 រៀល

**xii.** Stay and Enjoy Limited (SEL) ត្រូវបានចុះបញ្ជីដោយត្រឹមត្រូវជាមួយអាជ្ញាធរពន្ធដារជាអ្នកជាប់ពន្ធតាមរបបពិត។ សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនគឺសណ្ឋាគារ ដោយមានសេវាភោជនីយដ្ឋាន បា(bar) និងម៉ាស្សា។ ខាងក្រោមនេះជាសេចក្តីលម្អិតនៃការលក់ និងទិញរបស់ SEL ក្នុងខែធ្នូ ឆ្នាំ2016។

| **ទិនានុប្បវត្តិលក់ - ខែធ្នូ ឆ្នាំ2016** | |
|---|---|
| **សេចក្តីបរិយាយ** | **ចំនួនរួមបញ្ចូល អតប និងពន្ធអាករពាក់ព័ន្ធ (ដុល្លា)** |
| ចំណូលសណ្ឋាគារ: | |
| ថ្លៃបន្ទប់ | 99,000 |
| ថ្លៃចេញពីសណ្ឋាគារយឺត (Late Check-out) | 880 |
| ថ្លៃថែមគ្រែ | 1,375 |
| ថ្លៃបោកគក់ | 495 |

| **ទិនានុប្បវត្តិទិញ - ខែធ្នូ ឆ្នាំ2016** | |
|---|---|
| **សេចក្តីបរិយាយ** | **ចំនួនរួមបញ្ចូល អតប ដែលត្រូវអនុវត្ត (ដុល្លា)** |
| | |
| ថ្លៃជួល | 16,500 |
| បៀរស្រា | 10,300 |
| ថ្លៃប្រឹក្សាសារពើពន្ធ | 990 |
| រថយន្ត (តិចជាង 10កៅអី) | 11,000 |

| | |
|---|---|
| <u>ភោជនីយដ្ឋាន និង បា(bar)៖</u> | |
| អាហារ | 49,500 |
| ទឹកសុទ្ធ | 3,300 |
| ទឹកផ្លែឈើស្រស់ | 4,400 |
| ស្រាបៀ | 17,600 |
| ស្រាវីស្គី (Whisky) | 6,600 |
| ស្រាសមប៉ាញ (Champagne) | 4,950 |
| បារី | 3,300 |
| <u>ស្ប៉ា និងម៉ាស្សា:</u> | |
| ថ្លៃម៉ាស្សា | 8,800 |

| | |
|---|---|
| បុព្វលាភធានារ៉ាប់រងលើរថយន្ត | 400 |
| ចំណាយទីផ្សារ | 759 |
| ថ្លៃសន្តិសុខ | 1,320 |
| ថ្លៃសេវាអ៊ីធើនែត(Internet Fee) | 550 |
| ថ្លៃសេវាទូរស័ព្ទលើតុ | 275 |
| សាំង | 1,500 |
| ថ្លៃការប្រាក់ធនាគារ | 1,500 |

**សម្គាល់៖**

1. ចំនួនលក់រួមបញ្ចូល អតប និងពន្ធអាករពាក់ព័ន្ធដែលត្រូវអនុវត្ត (គឺ អាករលើការស្នាក់នៅ 2% អាករបំភ្លឺ សាធារណៈ 3% និងអាករពិសេស 10%)។
2. ចំនួនទិញ រួមបញ្ចូលអតប ដែលត្រូវអនុវត្ត ប្រសិនបើមាន។ អ្នកផ្គត់ផ្គង់របស់ SEL គឺជាអ្នកជាប់ពន្ធតាមរបបពិតទាំងអស់ និងបានចេញវិក្កយបត្រយ៉ាងត្រឹមត្រូវ ដូចដែលបទប្បញ្ញត្តិពន្ធដារតម្រូវ មកអោយ SEL។
3. យោងតាមលិខិតប្រកាសអតប សម្រាប់ខែវិច្ឆិកា ឆ្នាំ2016 SEL មានឥណទានអតប លើធាតុចូលយោងចំនួន 800ដុល្លា។

ផ្អែកតាម ប្រកាសលេខ 153 ប្រក.សហវ.ពដ ចុះថ្ងៃទី15 ខែកុម្ភៈ ឆ្នាំ2001 តើប្រាក់ចំណូលណាខ្លះរបស់ SEL ត្រូវជាប់អាករពិសេស?

1. ថ្លៃបន្ទប់
2. បារី
3. ថ្លៃម៉ាស្សា

A. 1
B. 2
C. 3
D. ចំលើយទាំងអស់ខាងលើ

xiii. ផ្អែកតាមព័ត៌មានខាងលើ បំណុល/(ឥណទាន)អតបរបស់ SEL សម្រាប់ខែធ្នូ ឆ្នាំ2016 មានចំនួន៖

A. 17,366 ដុល្លា
B. 14,571 ដុល្លា
C. 15,546 ដុល្លា
D. 15,571 ដុល្លា

xiv. ផ្អែកតាមព័ត៌មានខាងលើ បំណុលអាករពិសេសរបស់ SEL សម្រាប់ខែធ្នូ ឆ្នាំ2016 មានចំនួន៖

A. 727 ដុល្លា
B. 800 ដុល្លា
C. 880 ដុល្លា
D. គ្មានចំលើយណាមួយខាងលើ

xv. ផ្អែកតាមព័ត៌មានខាងលើ បំណុលអាករបំភ្លឺសាធារណៈរបស់ SEL សម្រាប់ខែធ្នូ ឆ្នាំ2016 មានចំនួន៖

A. 974 ដុល្លា
B. 859 ដុល្លា
C. 885 ដុល្លា
D. គ្មានចំលើយណាមួយខាងលើ

**(សរុប 30 ពិន្ទុ)**

សំណួរទី2- សំណួរជ្រើសរើស (សំណួរនីមួយៗទទួលបាន 2ពិន្ទុ)

i. ផ្អែកតាមផ្នែកទី9.5 នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ការខាតសារពើពន្ធអាចយោង និងកាត់កងប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ក្នុងករណីវាបំពេញនូវល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួន។ តើល័ក្ខខ័ណ្ឌខាងក្រោមណាខ្លះដែលអនុវត្តតាមប្រកាសនេះ៖

1. ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាសពន្ធ ប៉ុន្តែមិនតម្រូវឱ្យមានការបញ្ជាក់អះអាងដោយបញ្ជីឯកសារគណនេយ្យនោះទេ។
2. អ្នកជាប់ពន្ធដែលត្រូវទទួលរងការកំណត់ពន្ធ (ការកំណត់ពន្ធឡើងវិញជាធម្មតា) ដោយរដ្ឋបាលសារពើពន្ធ មិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ពីមុនមកកាត់ចេញទេ។
3. ការខាតបង់ត្រូវមានចុះក្នុងលិខិតប្រកាសពន្ធ និងលិខិតប្រកាសនេះត្រូវបានដាក់ជូនរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារ បានកំណត់ឱ្យដាក់លិខិតប្រកាសនេះ។
4. អ្នកជាប់ពន្ធអាចកំណត់ឆ្នាំជាប់ពន្ធដើម្បីកាត់កងចំនួនខាតសារពើពន្ធ។
5. ប្រសិនបើដោយមូលហេតុណាមួយ អ្នកជាប់ពន្ធមិនបានយោងការខាតបង់ទៅកាត់ចេញនឹងប្រាក់ចំណេញនៃឆ្នាំជាប់ពន្ធណាមួយដែលច្បាប់បានអនុញ្ញាតឱ្យកាត់ចេញ ការខាតបង់នេះអាចយោងទៅកាត់ចេញពីប្រាក់ចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ៗទៀតបានទេ។

A. 1 និង 5

B. 2, 4 និង 5

C. 2, 3 និង 4

D. 3 និង 5

ii. យោងតាមមាត្រា 116 និង 117 នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញនៃរយៈពេលសារពើពន្ធមួយ ដែលស្ថិតក្នុងរយៈពេលដែលត្រូវអនុវត្ត។ តើចំណុចខាងក្រោមណាខ្លះមិនត្រឹមត្រូវ៖

1. សារពើពន្ធអាចត្រូវបានធ្វើការកំណត់ឡើងវិញក្នុងរយៈពេលបីឆ្នាំ ក្រោយកាលបរិច្ឆេទដាក់លិខិតប្រកាស សារពើពន្ធ
2. សារពើពន្ធអាចត្រូវបានធ្វើការកំណត់ឡើងវិញក្នុងរយៈពេលប្រាំឆ្នាំ ក្រោយកាលបរិច្ឆេទដាក់លិខិតប្រកាសសារពើពន្ធ
3. សារពើពន្ធអាចត្រូវបានធ្វើការកំណត់ឡើងវិញក្នុងរយៈពេលប្រាំឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ
4. សារពើពន្ធអាចត្រូវបានធ្វើការកំណត់ឡើងវិញក្នុងរយៈពេលដប់ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

5. សារពើពន្ធអាចត្រូវបានធ្វើការកំណត់ឡើងវិញក្នុងរយៈពេលណាមួយក៏បានតាមការយល់ព្រមជាលាយល័ក្ខអក្សររបស់អ្នកជាប់ពន្ធ។

A. 1 និង 4

B. 1, 3 និង 5

C. 2, 4 និង 5

D. 2 និង 3

iii. ក្នុងខែតុលា ឆ្នាំ2015 XYZ Co., Ltd (XYZ) ជារោងចក្រផលិតស្រាបៀមួយ ត្រូវបានទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ នៅក្នុងខែដដែល រោងចក្រនេះបានទិញម៉ាស៊ីនផលិតស្រាបៀមួយក្នុងតម្លៃ 5,500,000ដុល្លា។ ក្រុមប្រឹក្សាភិបាលរបស់ XYZ បានជ្រើសរើសប្រើប្រាស់រំលស់ពិសេសជាការលើកទឹកចិត្តវិនិយោគរបស់ខ្លួន។ ម៉ាស៊ីននេះត្រូវបានដាក់ឱ្យប្រើប្រាស់មួយខែក្រោយមក។ តើចំនួនរំលស់សារពើពន្ធសម្រាប់ឆ្នាំការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 ខាងក្រោមណាមួយជាចំនួនត្រឹមត្រូវ?

A. រំលស់ធម្មតា= 1,100,000ដុល្លា និងរំលស់ពិសេស= 1,760,000 ដុល្លា

B. រំលស់ធម្មតា= 0ដុល្លា និងរំលស់ពិសេស= 2,200,000 ដុល្លា

C. រំលស់ធម្មតា= 1,100,000ដុល្លា និងរំលស់ពិសេស= 0 ដុល្លា

D. រំលស់ធម្មតា= 660,000ដុល្លា និងរំលស់ពិសេស= 2,200,000 ដុល្លា

iv. STAR ជាក្រុមហ៊ុនចុះបញ្ជីដោយត្រឹមត្រូវជាមួយសាខាពន្ធដារខណ្ឌដូនពេញជាអ្នកជាប់ពន្ធតូច ដែលមានផលរបរប្រចាំឆ្នាំ 500 លានរៀល (ប្រហែល 125,000 ដុល្លា ដោយប្រើប្រាស់អត្រាប្តូរប្រាក់ក្នុង 1 ដុល្លា = 4,000 រៀល)។ ក្នុងខែកញ្ញា ឆ្នាំ2016 STAR បានកើតឡើងនូវចំណាយដូចខាងក្រោម៖

- ចំណាយបៀវត្សទៅបុគ្គលិកម្នាក់ ចំនួន 500ដុល្លា
- ថ្លៃប្រឹក្សា បង់ទៅទីប្រឹក្សារូបវន្តបុគ្គល ចំនួន 300ដុល្លា
- ជួលការិយាល័យ ចំនួន 350ដុល្លា មិនរួមបញ្ចូល អតប
- ចំណាយការប្រាក់បង់ទៅធនាគារក្នុងស្រុក ចំនួន 400ដុល្លា
- ទិញម៉ាស៊ីនថតចម្លងឯកសារសម្រាប់ការប្រើប្រាស់របស់ក្រុមហ៊ុន ចំនួន 165 ដុល្លា រួមបញ្ចូល អតប

ចូរគណនាបំណុលពន្ធកាត់ទុក(WHT)របស់ STAR សម្រាប់ខែកញ្ញា ឆ្នាំ2016៖

A. 50 ដុល្លា

B. 35 ដុល្លា

C. 80 ដុល្លា

D. 95 ដុល្លា

v. តើចំណុចខាងក្រោមណាខ្លះមិនត្រឹមត្រូវ?

1. កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិច សហ្វវែរ(software) និងបរិក្ខារទុកដាក់ទិន្នន័យ ត្រូវធ្វើរំលស់តាមវិធីថយចុះជាលំដាប់ តាមអត្រា៤0% នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ក្នុងថ្នាក់នេះ។
2. ទ្រព្យសកម្មរូបីផ្សេងទៀតទាំងអស់ត្រូវរំលស់ តាមវិធីថយចុះជាលំដាប់ តាមអត្រា25%នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ក្នុងថ្នាក់នេះ។
3. រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារឹម និងបរិក្ខាការិយាល័យ ត្រូវធ្វើរំលស់តាមវិធីថយចុះជាលំដាប់ តាមអត្រា 20% នៃមូលដ្ឋានរំលស់នៅក្នុងមួយឆ្នាំ ក្នុងថ្នាក់នេះ។
4. អាគារ រចនាសម្ព័ន្ធរបស់អាគារ និងសំណង់ដែលជាសមាសភាគនៃអាគារ ត្រូវធ្វើរំលស់តាមអត្រា 5% ក្នុងមួយឆ្នាំនៃបរិយាទានលទ្ធកម្ម តាមវិធីរំលស់ថយចុះជាលំដាប់ ។

A. 1, 2 និង 4
B. 1, 3 និង 4
C. 1 និង 4
D. ចម្លើយទាំងអស់ខាងលើ

vi. ABD Co., Ltd ជាក្រុមហ៊ុនដែលចុះបញ្ជីយ៉ាងត្រឹមត្រូវជាមួយអាជ្ញាធរកម្ពុជាក្នុងខែ មករា ឆ្នាំ2014 ដែលឆ្នាំហិរញ្ញវត្ថុ (financial year) បញ្ចប់នៅថ្ងៃទី31 ខែធ្នូ។ ក្នុងខែសីហា ឆ្នាំ2015 ក្រុមប្រឹក្សាភិបាលរបស់ ABD បានសម្រេចចិត្តកែប្រែឆ្នាំហិរញ្ញវត្ថុបញ្ចប់នៅថ្ងៃទី30 ខែកញ្ញា ដើម្បីបន្សុីគ្នានឹងឆ្នាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធំ(Group)។ ABD បានស្នើសុំឱ្យអាជ្ញាធរពាក់ព័ន្ធ រួមទាំងអពដ អនុម័តការកែប្រែឆ្នាំហិរញ្ញវត្ថុមកបញ្ចប់នៅថ្ងៃទី30 ខែកញ្ញាវិញ។ អពដបានអនុម័តការកែប្រែនៅថ្ងៃទី28 ខែកញ្ញា ឆ្នាំ2015 ហើយឆ្នាំហិរញ្ញវត្ថុថ្មីចាប់ផ្តើមមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី1 ខែតុលា ឆ្នាំ2015។

ផ្អែកតាមលិខិតប្រកាសពន្ធលើប្រាក់ចំណេញឆ្នាំ2014 ទ្រព្យសកម្មរបស់ ABD មានដូចខាងក្រោម៖

| **ថ្នាក់ទ្រព្យសកម្ម** | **តម្លៃនៅសល់មិនទាន់រំលស់ (ដុល្លារ)** |
|---|---|
| ថ្នាក់ 2 – កុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រ | 350,000 |
| ថ្នាក់3 – បរិក្ខាការិយាល័យ និងរថយន្ត | 24,000 |
| ថ្នាក់ 4 – ទ្រព្យសកម្មរូបីផ្សេងទៀត | 200,000 |
| **សរុប** | **574,000** |

ក្នុងអំឡុងឆ្នាំ2015 មិនមានការទិញបន្ថែម ឬលក់ចេញនៃទ្រព្យសកម្មទេ។

តើរំលស់សារពើពន្ធដែលអនុវត្តសម្រាប់ឆ្នាំជាប់ពន្ធបញ្ចប់ត្រឹមថ្ងៃទី30 ខែកញ្ញា ឆ្នាំ2015( ដោយសន្មតថាក្នុងឆ្នាំ2015 មាន365ថ្ងៃ ) មានចំនួនប៉ុន្មាន ?

A. 221,000 ដុល្លារ

B. 165,296 ដុល្លារ

C. 229,800 ដុល្លារ

D. 171,878 ដុល្លារ

vii. Red Dragon Co., Ltd. ( Red Dragon ) ជាសណ្ឋាគារផ្កាយបួនដែលបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។ បន្ថែមពីចំណូលដែលបានពីការជួលបន្ទប់ Red Dragon ក៏មានផ្តល់សេវាម៉ាស្សាទៅអតិថិជនផងដែរ។

ពន្ធអាករប្រចាំខែខាងក្រោមត្រូវបានអនុវត្តលើចំណូលរបស់អ្នកជាប់ពន្ធ៖

1. អតប តាមអត្រា 10%
2. ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ តាមអត្រា 1%
3. អាករលើការស្នាក់នៅ តាមអត្រា 2%
4. អាករពិសេស តាមអត្រា 10%

តើពន្ធអាករខាងលើណាខ្លះត្រូវអនុវត្តលើចំណូល Red Dragon ដែលបានពីសេវាជួលបន្ទប់ស្នាក់នៅ ?

A. 1, 2 និង 4

B. 1, 2, និង 3

C. 1 និង 2

D. 2 និង 3

viii. ក្នុងខែឧសភា ឆ្នាំ2016 Red Dragon បានចេញវិក្ក័យប័ត្រដូចខាងក្រោមទៅអតិថិជន។ វិក្ក័យប័ត្រទាំងនេះរួមបញ្ចូលពន្ធអាករដែលត្រូវអនុវត្តទាំងអស់ (អត្រាប្តូរប្រាក់ 1ដុល្លារ ៖4,063 រៀល )។

| **ចំនួនក្នុងវិក្ក័យប័ត្រ រួមបញ្ចូលពន្ធអាករទាំងអស់ (ដុល្លារ)** | |
|---|---|
| ចំណូលពីជួលបន្ទប់ | 150,000 ដុល្លារ |
| ចំណូលពីលក់ភេសជ្ជៈមានជាតិអាកុល | 50,500 ដុល្លារ |
| ចំណូលពីសេវាម៉ាស្សា | 18,000 ដុល្លារ |

ចូរគណនាបំណុលពន្ធអាករដែលត្រូវអនុវត្ត (វៀរលែងតែ អតប និងប្រាក់រំដោះពន្ធលើប្រាក់ចំណេញ) របស់ Red Dragon សម្រាប់ខែឧសភា ឆ្នាំ2016។

A. 25,838,811 រៀល

B. 21,774,145 រៀល
C. 22,181,380 រៀល
D. 22,340,649 រៀល

ix. យោងតាមមាត្រា 131 នៃច្បាប់ស្តីពីសារពើពន្ធ ពាក់ព័ន្ធនឹងពន្ធបន្ថែមចំពោះការបង់ពន្ធខ្វះ តើចំណុចខាងក្រោមណាខ្លះដែលត្រឹមត្រូវ?

1. បុគ្គលដែលមានការធ្វេសប្រហែស ត្រូវទទួលខុសត្រូវបង់ពន្ធបន្ថែមតាមអត្រា 10%នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ 2% ក្នុងមួយឆ្នាំ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះនោះមិនទាន់បានបង់។
2. បុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ត្រូវទទួលខុសត្រូវបង់ពន្ធបន្ថែមតាមអត្រា 25%នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ 2% ក្នុងមួយខែ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះនោះមិនទាន់បានបង់។
3. បុគ្គលដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ត្រូវទទួលខុសត្រូវបង់ពន្ធបន្ថែមតាមអត្រា 25%នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ 20% ក្នុងមួយឆ្នាំ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះនោះមិនទាន់បានបង់។
4. ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង 40% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ 2% ក្នុងមួយឆ្នាំ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

A. 1, 2 និង 3
B. 1, 3 និង 4
C. 1 និង 2
D. 2 តែប៉ុណ្ណោះ

x. ក្នុងខែមីនា ឆ្នាំ2016 Cigar Co., Ltd (Cigar) ដែលជាក្រុមហ៊ុនចែកចាយបារី បានចេញវិក្កយប័ត្រមួយទៅអ្នកលក់ដុំសំខាន់របស់ខ្លួន ក្នុងចំនួនទឹកប្រាក់ 600,000ដុល្លារ រួមបញ្ចូលពន្ធអាករទាំងអស់ សម្រាប់ការលក់បារីទាំងនេះ។ គណនេយ្យកររបស់ Cigar មិនប្រាកដថាតើចំនួនអាករបំភ្លឺសាធារណៈត្រូវបង់ទៅអាជ្ញាធរពន្ធដារចំនួនប៉ុន្មានទេ។

ចូរគណនាចំនួនទឹកប្រាក់អាករបំភ្លឺសាធារណៈ ដែលត្រូវបង់។

A. 15,887 ដុល្លារ
B. 17,476 ដុល្លារ
C. 16,364 ដុល្លារ

D. 18,000 ដុល្លារ

xi. ក្រុមហ៊ុន ABC Co., Ltd បានកត់ត្រាចំណូល និងចំណាយក្នុងបញ្ជីការគណនេយ្យក្នុងខែកក្កដា ឆ្នាំ2016 ដូចខាងក្រោម៖

**ចំណូល**

- ចំណូលពីការលក់ ចំនួន 500,000 ដុល្លារ មិនរួមបញ្ចូលអតប
- ប្រាក់កក់ចំនួន 2,200ដុល្លារ រួមបញ្ចូលអតប ពីអតិថិជនលក់ដុំមួយ សម្រាប់ការបញ្ជាទិញមួយ។ អតិថិជននឹងបង់នូវចំនួននៅសល់ នៅពេល ABC ប្រគល់ទំនិញក្នុងសប្តាហ៍ទីពីរ នៃខែសីហា ឆ្នាំ2016។
- ចំណូលការប្រាក់ពីគណនីសន្សំមានកាលកំណត់ចំនួន 900ដុល្លារ។

**ចំណាយ**

- ក្រុមហ៊ុន ABC នាំចូលពីការិយាល័យកណ្តាលចំនួន 600,000ដុល្លារ មិនរួមបញ្ចូលអតប
- ក្រុមហ៊ុន ABC បានបង់ថ្លៃជួលការិយាល័យចំនួន 2,000 ដុល្លារ ទៅម្ចាស់ផ្ទះ(lessor) រូបវន្តបុគ្គល។
- ចំណាយថ្លៃសាំងក្នុងខែចំនួន 2,200 ដុល្លារ រួមបញ្ចូលអតប
- រថយន្តមួយគ្រឿង (4កៅអី) សម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មថ្លៃ 22,000ដុល្លារ រួមបញ្ចូលអតប ទិញពីក្រុមហ៊ុនចុះបញ្ជីតាមរបបពិត។
- ថ្លៃបន្ទប់សណ្ឋាគារចំនួន 550 ដុល្លារ រួមបញ្ចូលអតប សម្រាប់ភ្ញៀវម្នាក់មកពីការិយាល័យ កណ្តាល។
- ថ្លៃអាហារពីក្រុមហ៊ុនក្នុងស្រុកមួយ សម្រាប់ពិធីជួបលៀងបុគ្គលិកប្រចាំឆ្នាំចំនួន 3,200 ដុល្លារ រួមបញ្ចូលអតប។

សម្រាប់គោលដៅខាងពន្ធដារ សន្មតថាវិក្ក័យប័ត្រទាំងអស់ត្រឹមត្រូវ តើ ABC អាចស្នើសុំអតបលើធាតុចូល ក្នុងខែកក្កដា ឆ្នាំ 2016 ចំនួនប៉ុន្មាន?

A. 60,181.18 ដុល្លារ
B. 62,540.90 ដុល្លារ
C. 60,000.00 ដុល្លារ
D. 62,250.00 ដុល្លារ

xii. ផ្អែកតាមព័ត៌មានខាងលើ ចូរគណនាឥណទាន/ចំនួនអតបដែលត្រូវបង់របស់ABC សម្រាប់ខែកក្កដា ឆ្នាំ2016។

A. ឥណទានអតបចំនួន 9,981.18 ដុល្លារ
B. ឥណទានអតបចំនួន 9,710.00 ដុល្លារ
C. ឥណទានអតបចំនួន 12,050.00 ដុល្លារ
D. ឥណទានអតបចំនួន 9,800.00 ដុល្លារ

xiii. GPH ជាសណ្ឋាគារផ្កាយប្រាំដែលស្ថិតក្នុងខេត្តសៀមរាបក្នុងព្រះរាជាណាចក្រកម្ពុជា។ សណ្ឋាគារនេះកាន់កាប់ភាគហ៊ុន 100% ដោយសណ្ឋាគារអន្តរជាតិដែលមានមូលដ្ឋានក្នុងប្រទេសសិង្ហបុរី។ GPH បានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម

អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងពាក់ព័ន្ធដទៃទៀតក្នុងខែមីនា ឆ្នាំ2008។ GPH ក៏ទទួលបាននូវល័ក្ខខ័ណ្ឌជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងឆ្នាំដដែល និងត្រូវបានផ្តល់នូវការលើកទឹកចិត្តវិនិយោគមួយចំនួន រួមទាំងរយៈពេលលើកលែងពន្ធ(ជាមួយនឹងរយៈពេលអាទិភាពមួយឆ្នាំ)។

GPH រកបានចំណូលលើកដំបូងរបស់ខ្លួនក្នុងឆ្នាំ2010។ ខាងក្រោមនេះជាស្ថានភាពខាត និងចំណេញរបស់ក្រុមហ៊ុន។

| ឆ្នាំ | ចំណេញជាប់ពន្ធ (ដុល្លារ) | ខាតសារពើពន្ធ (ដុល្លារ) |
|---|---|---|
| 2008 | - | 2,000,000 |
| 2009 | - | 2,000,000 |
| 2010 | - | 5,000,000 |
| 2011 | 800,000 | - |
| 2012 | - | 1,100,000 |
| 2013 | 1,000,000 | - |
| 2014 | 8,000,000 | - |

GPH មានចំនួនខាតយោងសារពើពន្ធសរុបនៅចុងការិយបរិច្ឆេទឆ្នាំ2014 គឺ៖

A. 300,000 ដុល្លារ
B. 200,000 ដុល្លារ
C. សូន្យ
D. 100,000 ដុល្លារ

xiv. សម្រាប់ការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 GPH មានចំណូលសរុបចំនួន 1,500,000 ដុល្លារ មិនរួមបញ្ចូលអតប ពីប្រភពចំណូលទាំងអស់ និងចំណេញសុទ្ធក្រោយគិតពន្ធ(net profit after income tax)ចំនួន 600,000 ដុល្លារ ក្រោយគិតនូវចំណុចដូចខាងក្រោម៖

a. រំលស់គណនេយ្យចំនួន 500,000 ដុល្លារ។
b. សំវិធានធនលើបំណុលជាប់សង្ស័យចំនួន 67,000 ដុល្លារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2014 និងត្រូវថយចុះចំនួន 12,000 ដុល្លារ ក្នុងកំឡុងការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2015។
c. ចំណេញពីការប្តូរប្រាក់(foreign exchange gain) រួមមាន៖
   - ចំណេញពីការប្តូរប្រាក់សម្រេចបានពីការបង់ពន្ធចំនួន 2,000 ដុល្លារ។
   - ចំណេញពីការប្តូរប្រាក់មិនសម្រេចបានចំនួន 680 ដុល្លារ ដោយសារការប្តូររូបិយវត្ថុបរទេសនៅចុងការិយបរិច្ឆេទ ។
d. គណនី"ចំណាយពន្ធលើប្រាក់ចំណូល(income tax expense)សរុប" បានកត់ត្រាជាចំណាយ(កត់ខាងឥណពន្ធ) ទៅក្នុងរបាយការណ៍ចំណូល (Income Statement) មានចំនួន125,000 ដុល្លារ។

គណនីនេះរួមមាន៖

- សំវិធានធនលើបំណុលពន្ធលើប្រាក់ចំណេញ ប៉ាន់ស្មានដោយ គណនេយ្យកររបស់ GPH សម្រាប់ការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 និង
- ប្រាក់ពន្ធកាត់ទុកកំណត់ឡើងវិញដែលបង់ខ្វះ បូកបន្ថែមទោសទណ្ឌ និងការប្រាក់ចំនួន5,000 ដុល្លារ បានបង់ទៅអាជ្ញាធរពន្ធដារក្នុងខែធ្នូ ឆ្នាំ2015 ដូចមានចែងក្នុងសេចក្ដីជូនដំណឹងនៃការកំណត់ពន្ធឡើងវិញស្ដីពីសវនកម្មសារពើពន្ធមានកម្រិតសម្រាប់ឆ្នាំ2014។

សន្មតថាវិលស់សារពើពន្ធរបស់ GPH មានចំនួន 700,000 ដុល្លារ ហើយនិងមិនមានការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ2015ទេ។ ចំណេញជាប់ពន្ធ /ខាតសារពើពន្ធរបស់ GPHសម្រាប់ឆ្នាំ2015 មានចំនួន៖

A. 512,320 ដុល្លារ
B. 312,320 ដុល្លារ
C. 307,320 ដុល្លារ
D. 507,320 ដុល្លារ

XV. White Bank Cambodia (WB កម្ពុជា) ត្រូវបានចុះបញ្ជីក្នុងប្រទេសកម្ពុជាជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងខែមករា ឆ្នាំ2016។ WB កម្ពុជា ជាបុត្រសម្ព័ន្ធរបស់ WB ថៃ (ធនាគារពាណិជ្ជមួយ) ។ WB កម្ពុជា បានកត់ត្រាសំវិធានលើប្រាក់កម្ចីសម្រាប់ឆ្នាំ2016 និងឆ្នាំ2017 ទៅតាមតម្រូវការរបស់ធនាគារកម្ពុជាដែលមានរាយលម្អិតដូចខាងក្រោម:

*សំវិធានធនលើប្រាក់កម្ចី (Provision on loans)*

| **បរិយាយ** | **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 (ដុល្លា)** | **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 (ដុល្លា)** |
|---|---:|---:|
| សំវិធានធនលើប្រាក់កម្ចីធម្មតា | 98,428 | 123,035 |
| សំវិធានធនលើប្រាក់កម្ចីពិសេស | 253,100 | 316,375 |
| សំវិធានធនលើប្រាក់កម្ចីក្រោមស្តង់ដា | 1,028,890 | 1,286,113 |
| សំវិធានធនលើប្រាក់កម្ចីដែលគួរឱ្យសង្ស័យ | 1,406,113 | 1,757,641 |
| សំវិធានធនលើប្រាក់កម្ចីខាតបង់ | 1,406,113 | 1,757,641 |
| **សរុប** | **4,192,644** | **5,240,805** |

WB កម្ពុជាបានធ្វើនិយ័តកម្មសំវិធានប្រាក់កម្ចីទៅក្នុងការគណនាពន្ធលើប្រាក់ចំណេញឆ្នាំ2016 របស់ខ្លួនយ៉ាងត្រឹមត្រូវ ទៅតាមប្រកាសលេខ 1535 សហវ ចុះថ្ងៃទី23 ខែធ្នូ ឆ្នាំ2016 ។ តើWB កម្ពុជាត្រូវធ្វើនិយ័តកម្មសំវិធានប្រាក់កម្ចីទៅក្នុងការគណនាពន្ធលើប្រាក់ចំណូល/ចំណេញឆ្នាំ2017 របស់ខ្លួនចំនួនប៉ុន្មាន?

A. USD 24,607
B. USD 63,275
C. USD 87,882
D. USD351,528

**(សរុប 30ពិន្ទុ)**

**សំណួរទី3៖**

Prime Global Investment (PGI) គឺជាក្រុមហ៊ុនសម្ព័ន្ធមួយ(Group Company) ដែលវិនិយោគលើអាជីវកម្មជាច្រើនលើសកលលោក។ អាជីវកម្មរបស់ក្រុមហ៊ុនរួមមាន សណ្ឋាគារផ្កាយ5 ការដឹកជញ្ជូនដីគោក និងសេវាទេសចរណ៍។ ដោយសារលក្ខខណ្ឌទីផ្សារ ក្រុមហ៊ុន PGI មានចំណាប់អារម្មណ៍ពង្រីកអាជីវកម្មរបស់ខ្លួនចូលមកប្រទេសកម្ពុជា ដោយផ្តោតសំខាន់លើសណ្ឋាគារ និងសេវាទេសចរណ៍។ លោក George ដែលជាអ្នកចាត់ចែងជាន់ខ្ពស់ (a group CEO) នៃក្រុមហ៊ុន PGI បានរៀបចំការសិក្សាទីផ្សារ អំពីគម្រោងវិនិយោគក្នុងប្រទេសកម្ពុជា។ ចំពោះការពិចារណាលើផ្នែកពន្ធដារ លោក George បានកត់សម្គាល់នូវព័ត៌មានគួរឱ្យចាប់អារម្មណ៍មួយចំនួនអំពីការអនុវត្តពន្ធដារដូចខាងក្រោម៖

- ប្រទេសកម្ពុជាអនុវត្តប្រព័ន្ធសារពើពន្ធស្វ័យប្រកាស
- អាជីវកម្មសណ្ឋាគារផ្កាយ5 អាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) ដែលមានសិទ្ធិទទួលបានការលើកទឹកចិត្តពន្ធដារមួយចំនួន រួមទាំងការលើកលែងពន្ធលើប្រាក់ចំណេញ។
- សកម្មភាពអាជីវកម្មដែលមានសក្តានុពលចំនួនពីរ អាចត្រូវបានធ្វើប្រតិបត្តិការក្រោមសហគ្រាសចុះបញ្ជីតែមួយក្នុងប្រទេស កម្ពុជា។

លោក George មានបំណងសិក្សាលម្អិតបន្ថែមអំពីការយល់ឃើញជាបឋមខាងលើនេះ។
សូមផ្តល់យោបល់លើចំណុចដូចខាងក្រោម ដោយផ្អែកលើបទប្បញ្ញត្តិពន្ធដារកម្ពុជា ដើម្បីផ្តល់ព័ត៌មានបន្ថែមដល់លោក George។

i. សូមពន្យល់ឱ្យបានលម្អិតអំពីរយៈពេលលើកលែងពន្ធ សម្រាប់គ.ល.គ។ ចម្លើយរបស់អ្នកត្រូវបញ្ចូលនូវរយៈពេលនៃការលើកលែងពន្ធ បូករួមទាំងវិធីនៃការគណនារយៈពេលទាំងនេះ។ **(4ពិន្ទុ)**

ii. ដោយសន្មតថាសកម្មភាពអាជីវកម្មចំនួនពីរ (គឺសណ្ឋាគារផ្កាយ5 ជាគ.ល.គ និងសេវាកម្មទេសចរណ៍) នឹងត្រូវប្រតិបត្តិដោយសហគ្រាសមួយ (គឺ PGI កម្ពុជា) ក្នុងប្រទេសកម្ពុជា សូមពន្យល់ដោយសង្ខេបពីវិធីដែលក្រុមហ៊ុនត្រូវកាន់កាប់កំណត់ត្រាគណនេយ្យ(accounting records) ព្រមជាមួយនឹងវិធីប្រកាសពន្ធអាកររបស់ខ្លួន (គឺពន្ធអាករប្រចាំខែ លិខិតប្រកាសពន្ធលើប្រាក់ចំណេញ និងពន្ធប៉ាតង់) សម្រាប់សកម្មភាពទាំងពីរ។ **(4ពិន្ទុ)**

iii. ស្ថិតក្រោមរបបស្វ័យប្រកាស អ្នកជាប់ពន្ធនឹងត្រូវជាប់សវនកម្មសារពើពន្ធចំពោះពន្ធអាករដែលខ្លួនប្រកាស។ សូមពន្យល់ថាតើរយៈពេលនៃលិខិតប្រកាសពន្ធណាខ្លះ ដែលអាជ្ញាធរពន្ធដារមានសិទ្ធិធ្វើសវនកម្ម? **(2ពិន្ទុ)**

**(សរុប 10 ពិន្ទុ)**

## សំណួរទី4៖

Lux Clock Co., Ltd (LCC) ជាក្រុមហ៊ុនលក់នាឡិកាដៃ និងព្យួរជញ្ជាំងទំនើប ដែលនាំចូលពីហុងកុង។ ក្រុមហ៊ុននេះបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធជាបុគ្គលជាប់អាករចាប់តាំងពីចុងឆ្នាំ2014។ ក្នុងខែមិថុនា ឆ្នាំ2017 ក្រុមហ៊ុនបានកត់ត្រាប្រតិបត្តិការដូចខាងក្រោម៖

| **ចំណូល:** | **USD** |
|---|---:|
| លក់នាឡិកាដៃឲ្យអ្នកចែកចាយដែលបានចុះបញ្ជីពន្ធដារ | 200,000 |
| ចំនួនលក់សរុបទៅអ្នកលក់រាយ រួមបញ្ចូលអតប | 330,000 |
| ចំណូលពីការជួសជុលនាឡិកាដៃ និងព្យួរជញ្ជាំង រួមបញ្ចូលអតប | 5,500 |

| **ចំណាយ:** | **USD** |
|---|---:|
| នាំចូលនាឡិកាដៃ និងព្យួរជញ្ជាំងពីហុងកុង | 700,000 |
| ប្រាក់ខែបុគ្គលិកសម្រាប់ខែមិថុនា ឆ្នាំ2017 | 100,000 |
| ទិញឡានតូច១គ្រឿង និងឡានដឹកទំនិញ ១គ្រឿងសម្រាប់ធ្វើទីផ្សារ (1) | 63,000 |
| ជួលអ្នកជំនាញពីហុងកុង និងក្រុមហ៊ុនក្នុងស្រុក (2) | 25,000 |
| កែលម្អហាង (3) | 5,000 |
| ទិញប្រេងម៉ាស៊ូតនិងសាំង រួមបញ្ចូលអតប | 29,900 |
| ផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍ | 13,000 |
| អ្នកលក់រាយស្នើឲ្យ LCC សងប្រាក់ដែលបានគិតលើស (4) | 11,000 |

### សម្គាល់

a. ទឹកប្រាក់ទាំងអស់មិនរួមបញ្ចូលអតបទេ លើកលែងតែមានចែងផ្សេងពីនេះ។
b. ការទូទាត់ឲ្យអ្នកផ្គត់ផ្គង់ជាប់អតប ទាំងអស់ មានវិក្កយបត្រអាករត្រឹមត្រូវ។

### ពត៌មានបន្ថែម :

c. ឥណទានអតបយោងពីខែឧសភា ឆ្នាំ2017 មានចំនួន 25,500 ដុល្លារ។
d. (1) ឡានតូច និងឡានដឹកទំនិញ ទិញពីក្រុមហ៊ុនចុះបញ្ជីអតប។ រថយន្តតូច Corolla 2014 សម្រាប់បុគ្គលិកផ្នែកផ្សាយពាណិជ្ជកម្ម ទៅខេត្ត ថ្លៃ 30,000 ដុល្លារ មិនរួមបញ្ចូលអតប ហើយឡានដឹកទំនិញសម្រាប់ការរៀបចំកម្មវិធីផ្សាយពាណិជ្ជកម្មថ្លៃ 33,000 ដុល្លារ មិនរួមទាំងអតប ។
e. (2) សេវាអ្នកជំនាញរយៈពេល2ខែមកពីហុងកុង ថ្លៃ 10,000 ដុល្លារ ចំនួននៅសល់ជាចំណាយសេវាបង់ឲ្យក្រុមហ៊ុនសិង្ហបុរីដែលបង្កើតឡើងនៅកម្ពុជា ។

f. [3] ម្ចាស់ក្រុមហ៊ុន LCC បានឲ្យមិត្តភក្តិចាស់របស់គាត់ដែលជាម្ចាស់ក្រុមហ៊ុនសំណង់ ធ្វើការកែលម្អរហាង ហើយពួកគាត់ធ្វើការកាត់កងទឹកប្រាក់ថ្លៃនាឡិការចំនួន 5,000 ដុល្លារ ជាមួយនឹងថ្លៃសេវា 10,000 ដុល្លារហើយចំនួនដែលនៅសល់ទូទាត់ជាសាច់ប្រាក់។

g. [4]គណនេយ្យកររបស់ក្រុមហ៊ុន LCC បានចេញវិក្កយបត្រគិតលុយលើសពីអ្នកលក់រាយចំនួន 11,000 ដុល្លា រួមបញ្ចូលអតប ដែលមានចំនួនច្រើនជាងថ្លៃដើម។ លើសពីនេះ គណនេយ្យករក៏បានប្រកាសនិងបង់ពន្ធជូននាយកដ្ឋានសារពើពន្ធក្នុងខែឧសភា ឆ្នាំ2017 ហើយផងដែរ។ នៅថ្ងៃទី24 ខែមិថុនា អ្នកលក់រាយរកឃើញថា នាងបានបង់លើសចំនួនដែលបានគិតក្នុងវិក្កយបត្រ។ ក្រោយមកនាងក៏បានស្នើសុំឲ្យក្រុមហ៊ុន LCC បង្វិលលុយលើសនេះសងមកគាត់វិញ។

**សំនួរ**

គណនាអាករលើតម្លៃបន្ថែម ដែល LCC ត្រូវបង់សម្រាប់ខែមិថុនា ឆ្នាំ2017។ **(14ពិន្ទុ)**

**សំណួរទី5**

អ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ(Financial Controller)នៃ Duba Co., Ltd. (Duba ឬ ក្រុមហ៊ុន) កត់សម្គាល់ឃើញថាការធ្វើសវនកម្មសារពើពន្ធកាន់តែរឹតបន្តឹង និងយល់ឃើញថាលិខិតប្រកាសសារពើពន្ធរបស់អ្នកស្រីមិនបានរៀបចំឱ្យបានត្រឹមត្រូវទៅតាមបទប្បញ្ញត្តិសារពើពន្ធកម្ពុជាទេ។ ដូចនេះ អ្នកស្រីបានទាក់ទងអ្នក ដែលជាទីប្រឹក្សាសារពើពន្ធ ឱ្យជួយអ្នកស្រីដើម្បីកំណត់ និងកែតម្រូវចំណុចដែលមិនស្របច្បាប់ទៅតាមការចាំបាច់ ដើម្បីជៀសវាងទោសទណ្ឌក្នុងកំឡុងពេលសវនកម្មសារពើពន្ធ។

ខាងក្រោមនេះជារបាយការណ៍ចំណូលការិយបរិច្ឆេទថ្ងៃទី31 ខែធ្នូ ឆ្នាំ2015៖

| | **ដុល្លារ** |
|---|---:|
| **ចំណូល** | |
| ចំណូលពីសេវាកម្មទីផ្សារ និងសេវាផ្តល់អាជ្ញាប័ណ្ណ | 1,150,000 |
| ចំណូលការប្រាក់ | 20,000 |
| ចំណូលផ្សេងៗ | 70,000 |
| **សរុប** | **1,240,000** |
| | |
| **ចំណាយប្រតិបត្តិការ** | |
| បៀវត្សបុគ្គលិក (រួមបញ្ចូលបៀវត្សខែចុងក្រោយបង្គរចំនួន 80,000ដុល្លារ ដែលត្រូវទូទាត់ក្នុងពាក់កណ្តាលខែមីនា ឆ្នាំ2016) | (700,000) |
| អំណោយ/វិភាគទានសប្បុរសធម៌ | (15,000) |
| រំលស់ | (250,000) |
| គ្រឿងផ្គត់ផ្គង់ការិយាល័យ | (19,000) |
| សន្តិសុខ | (13,500) |
| ខាតគណនេយ្យចំពោះការលក់ទ្រព្យសកម្ម | (22,000) |
| ចំណាយការប្រាក់លើប្រាក់ខ្ចី | (200,000) |
| **សរុប** | **(1,219,500)** |
| | |
| **ចំណេញគណនេយ្យមុនគិតពន្ធ** | **20,500** |
| | |
| ចំណាយពន្ធលើប្រាក់ចំណេញ | (4,100) |
| | |
| **ចំណេញគណនេយ្យក្រោយគិតពន្ធ** | **16,400** |

## សម្គាល់៖

1. Duba បានផ្តល់ជាវិភាគទានចំនួន 10,000 ដុល្លារ ទៅកាកបាទក្រហមប្រជាជន និងចំនួន5,000 ដុល្លារ ផ្តល់ជាអំណោយទៅជនក្រីក្រដោយផ្ទាល់។

2. Duba បានលក់ភាគទុនចំនួន 5% ក្នុងក្រុមហ៊ុនមួយក្នុងឆ្នាំ2015។ ការលក់ចេញធ្វើឱ្យមានតម្លៃលើសមូលធន(capital gain) ចំនួន 25,000 ដុល្លារ (ដែលផលពីការលក់(sale proceed)គឺ 400,000ដុល្លារ)។ គណនេយ្យកររបស់ Duba បានមើលរំលង និងមិនបានកត់ត្រាប្រតិបត្តិការទាំងនេះ ក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ2015 ទេ។

   បន្ថែមពីនេះ ក្រោយពីលក់ទ្រព្យសកម្ម Duba បានបន្តទទួលបានការទូទាត់ភាគលាភក្រោយគិតពន្ធ ពីក្រុមហ៊ុនខាងលើតាមប្រភាគភាគរយនៃភាគទុនរបស់ខ្លួន។ ក្នុងឆ្នាំ2015 Duba បានទទួលភាគលាភចំនួន 70,000 ដុល្លារ ដែលត្រូវបានកត់ត្រាក្នុងគណនី "ចំណូលផ្សេងៗ"។

3. ចំណាយរំលស់គឺជារំលស់ទ្រព្យសកម្មទាំងអស់នៅក្នុងឆ្នាំ។

4. Duba បានទទួលប្រាក់ខ្ចីសម្រាប់វិនិយោគក្នុងឆ្នាំ2017 ចំនួន 1.5 លានដុល្លារ ក្នុងអត្រាការប្រាក់ 13% ក្នុងមួយឆ្នាំ ក្នុងឆ្នាំ2010 ពីធនាគារមិនទាក់ទិនក្នុងស្រុកមួយ ដើម្បីផ្តល់ហិរញ្ញប្បទានលើកង្វះសាច់ប្រាក់ក្នុងប្រតិបត្តិការអាជីវកម្ម។ នៅថ្ងៃទី1 ខែមករា ឆ្នាំ2015 Duba ទទួលបានប្រាក់ខ្ចីបន្ថែមពីធនាគារក្រៅស្រុកចំនួន 100,000 ដុល្លារ ក្នុងអត្រាការប្រាក់ 5% ក្នុងមួយឆ្នាំ។ កម្ចីថ្មីនេះខ្ចីធ្វើឡើងសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ម្ចាស់ភាគទុន ក្នុងការវិនិយោគទិញលក់ភាគហ៊ុនបរទេស (overseas stock exchange)។ Duba បានបង់ការប្រាក់តាំងពីឆ្នាំ2015។

   ចំណាយការប្រាក់ប្រចាំឆ្នាំចំពោះប្រាក់ខ្ចីទាំងអស់បានទូទាត់ទាំងស្រុង យ៉ាងយូរបំផុតនៅចុងខែធ្នូ ឆ្នាំ2015 និងបានកត់ត្រាបញ្ចូលក្នុងគណនី "ចំណាយការប្រាក់លើកម្ចី"។

5. ក្រុមហ៊ុនបានចំណាយអស់ 7,000 ដុល្លារ លើថ្លៃបន្ទប់ និងអាហារ សម្រាប់សម្រួលដល់ការស្នាក់នៅរបស់អតិថិជនមួយក្រុមដែលមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា។ ស្រដៀងគ្នានឹងចំណុចទី2 ខាងលើ គណនេយ្យកររបស់ Duba មិនបានកត់ត្រាប្រតិបត្តិការនេះក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ2015 របស់ខ្លួនទេ។

6. ចំណាយលើគ្រឿងផ្គត់ផ្គង់ការិយាល័យចំនួន 1,500ដុល្លារ បានកើតឡើងដោយបុគ្គលិកទទួលភ្ញៀវ(Receptionist) ប៉ុន្តែនាងបានធ្វើឱ្យបាត់ឯកសារបញ្ជាក់អំណះអំណាង (គឺវិក្កយប័ត្រ)។

7. ក្នុងឆ្នាំ2015 ក្រុមហ៊ុនមេរបស់ Duba បានលក់ឡានចំនួនពីរគ្រឿង ទៅឱ្យ Duba ដើម្បីដឹកក្រុមការងារផ្នែកទីផ្សារ និងផ្នែកលក់ ។ ចំណាយផ្ទេរសរុបមានចំនួន 30,000 ដុល្លារ រួមបញ្ចូលទាំងពន្ធនាំចូល(import tax) និងចំណាយថ្លៃដឹកជញ្ជូន វៀរលែងតែអតប។ ការិយាល័យកណ្តាលក៏បានរៀបចំវគ្គបណ្តុះបណ្តាលមួយសម្រាប់ក្រុមការងារផ្នែកទីផ្សារ ដែលចំណាយអស់ទឹកប្រាក់ចំនួន 2,300ដុល្លារ។ ដូចនេះ Duba ជំពាក់ក្រុមហ៊ុនមេរបស់ខ្លួនសរុបចំនួន 32,300ដុល្លារ ដែល Duba គ្រោងនឹងបង់ក្នុងខែសីហា ឆ្នាំ2016។

8. ខាងក្រោមនេះជាទ្រព្យសកម្មចុះបញ្ជីសម្រាប់គោលដៅខាងពន្ធដារគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2015៖

| ទ្រព្យសកម្ម | ថ្នាក់ 1 | ថ្នាក់ 2 | ថ្នាក់ 3 | ថ្នាក់ 4 |
|---|---|---|---|---|
| | ដុល្លារ | ដុល្លារ | ដុល្លារ | ដុល្លារ |
| ថ្លៃដើមប្រវត្តិសាស្ត្រ | 1,630,000 | 230,000 | 82,200 | 49,000 |
| រំលស់សារពើពន្ធបូកយោង | 55,000 | 35,000 | 13,500 | 6,500 |
| ផលពីលក់ទ្រព្យសកម្មបូកយោង | - | - | - | - |

នៅក្នុងឆ្នាំ ក្រុមហ៊ុនបានទិញសាឡុង (sofa) មួយឈុតក្នុងតម្លៃ 6,000 ដុល្លារ កុំព្យូទ័រយួរដៃបីគ្រឿងក្នុងតម្លៃ3,000 ដុល្លារសម្រាប់បុគ្គលិកជនបរទេសប្រើប្រាស់ និងតំឡើងបន្ទប់ប្រជុំចំនួនពីរបន្ថែមទៀត ដែលចំណាយអស់ 20,000 ដុល្លារ ក្នុងមួយបន្ទប់។ ឡានចំនួនពីរគ្រឿងក្នុងតម្លៃ 35,000 ដុល្លារ បានលក់ទៅឱ្យមិត្តភ័ក្ត្ររបស់និយោជិតក្នុងតម្លៃ20,000 ដុល្លារ។

9. ខាងក្រោមនេះជាកាលវិភាគខាតសារពើពន្ធ ដែលដកស្រង់ពីលិខិតប្រកាសពន្ធលើប្រាក់ចំណេញឆ្នាំ2014។

| | 2010 | 2011 | 2012 | 2013 | 2014 |
|---|---|---|---|---|---|
| ខាតសារពើពន្ធយោង (ដុល្លារ) | 10,000 | 12,000 | 15,000 | 5,000 | 8,500 |

ចាប់តាំងពីក្រុមហ៊ុនត្រូវចុះបញ្ជីរហូតដល់ចុងឆ្នាំ2014 សកម្មភាពអាជីវកម្មតែមួយគត់របស់ Duba គឺលក់ផលិតផលនាំចូលពីក្រុមហ៊ុនមេ។ ដោយសារការប្រកួតប្រជែងទីផ្សារមានសភាពខ្លាំងក្លា និងជាក់ស្តែងដែលក្រុមហ៊ុនទទួលរងនូវការខាតបង់អស់រយៈពេលប្រាំឆ្នាំជាប់ៗគ្នា ក្រុមការងារផ្នែកគ្រប់គ្រងសម្រេចចិត្តឈប់លក់ផលិតផលទាំងនេះទាំងស្រុង។ ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2015 ក្រុមហ៊ុនបានផ្លាស់ប្តូរសកម្មភាពអាជីវកម្មរបស់ខ្លួន ដោយផ្តល់តែសេវាកម្មទីផ្សារ និងសេវាផ្តល់អាជ្ញាប័ណ្ណតែប៉ុណ្ណោះទៅហាងលក់ទំនិញ(outlets) តតិយជនដែលនាំចូលផលិតផលដោយផ្ទាល់ពីក្រុមហ៊ុនមេរបស់ Duba ដើម្បីចាត់ចែងលក់ក្នុងប្រទេសកម្ពុជា។ Duba បានចុះបញ្ជីពីការកែប្រែនេះជាមួយអាជ្ញាធរពន្ធដារ។

**ព័ត៌មានផ្សេងទៀត៖**

ក) អពដ បានកំណត់អត្រាការប្រាក់កម្ចីទីផ្សារសម្រាប់ឆ្នាំ2015 គឺ 10% ក្នុងមួយឆ្នាំ។

ខ) ចំណាយការប្រាក់ពីឆ្នាំមុនត្រូវបានប្រើប្រាស់ទាំងអស់។

គ) Duba បង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញទៅអពដ លើចំណូលពីទីផ្សារ និងសេវាផ្តល់អាជ្ញាប័ណ្ណរបស់ខ្លួនប៉ុណ្ណោះ។

ឃ) ចំណូល និងចំណាយទាំងអស់ មិនរួមបញ្ចូលអតប រៀវលែងតែមានការបញ្ជាក់ជូន។

**សំណួរ៖**

ចូរគណនាបំណុលពន្ធលើប្រាក់ចំណេញរបស់ Duba ឡើងវិញសម្រាប់ការិយបរិច្ឆេទឆ្នាំ2015 ដោយផ្អែកលើព័ត៌មានដែលផ្តល់ឱ្យខាងលើ។ ពន្ធអប្បបរមា មិនតម្រូវឱ្យគណនាទេ។ **(20ពិន្ទុ)**

**(សរុប 20ពិន្ទុ)**